ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៧៦ ព.ណ.អវ.ប្រក

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រកាសលេខ ០៤៧ MOC / SM 2013 ស្តីពីការបិទស្លាកថ្លៃ លើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៨អនក្រ.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែប្រែកំរងសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- ប្រកាសលេខ ១៦៤៤ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ប្រកាសលេខ ២៦៦ ពណ.បល.ប្រក ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មការងារគ្រប់គ្រងការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស ជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

- ប្រកាសលេខ ០៤៧ MOC / SM 2013 ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ
- តម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១~.** ត្រូវបានកំណត់ឱ្យបិទស្លាកថ្លៃលើមុខទំនិញ និងសេវាទាំងអស់ដែលបានចរាចរនៅលើទីផ្សារ សំដៅធានាដល់យន្តការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារសេរី ការប្រកួតប្រជែងដោយសមធម៌ និងការលើកស្ទួយដល់ចរាចររូបិយវត្ថុក្នុងស្រុក(ប្រាក់រៀល) ក្នុងគោលបំណងបម្រើដល់ផលប្រយោជន៍ប្រជាជន និងអ្នកប្រើប្រាស់ទូទៅ។

**ប្រការ ២~.** ពាណិជ្ជករ អាជីវករ សេវាករទាំងអស់ ដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែបិទស្លាកថ្លៃលើគ្រប់មុខទំនិញ និងសេវារបស់ខ្លួនជាប្រាក់រៀលជាចាំបាច់។

**ប្រការ ៣~.** ក្នុងករណីទីតាំងពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មមិនជាប់ពន្ធ(Duty free) ដែលមានការអនុញ្ញាតដោយរាជរដ្ឋាភិបាល ចាំបាច់ត្រូវបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស ម្ចាស់ទីតាំងពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មទាំងនោះ ត្រូវមកសុំការអនុញ្ញាតពីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដែលមានទីតាំងអាជីវកម្ម សេវាកម្ម ស្ថិតនៅ។

**ប្រការ ៤~.** លិខិតអនុញ្ញាតឱ្យបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស មានសុពលភាពរយៈពេល ០១ ឆ្នាំ។ លិខិតអនុញ្ញាតិដែលហួសសុពលភាព ចាំបាច់ត្រូវសុំការអនុញ្ញាតិសារជាថ្មីពីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ។

**ប្រការ ៥~.** បែបបទសុំលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេសមានដូចខាងក្រោមៈ
- ពាក្យស្នើសុំលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស ចំនួន ០១ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតអាជីវកម្មផ្សេងៗចំនួន ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន(បើជាជនបរទេស) ចំនួន ០១ច្បាប់
- ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ (ថតចម្លង) ចំនួន ០១ច្បាប់
- រូបថត ទំហំ ៤ × ៦ ចំនួន ០៣សន្លឹក

**ប្រការ ៦~.** ពាណិជ្ជករ អាជីវករ និងសេវាករ ជាម្ចាស់ហាងលក់ទំនិញរួចពន្ធ (Duty free shops) ដែលសុំលិខិតអនុញ្ញាតិបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស ត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ដូចមានចែងនៅក្នុងកម្រងសេវាសាធារណៈក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៧~.** គ្រប់ពាណិជ្ជករ អាជីវករ និងសេវាករទាំងឡាយ ដែលមិនបានអនុវត្តតាមប្រកាសនេះ ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

**ប្រការ ៨~.** នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន អគ្គនាយកដ្ឋានកាំកុងត្រូល និងមន្ទីរពាណិជ្ជកម្មគ្រប់រាជធានី-ខេត្ត ត្រូវរួមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ចុះត្រួតពិនិត្យ និងណែនាំអំពីការបិទស្លាកថ្លៃ ជាប្រចាំរៀងរាល់ខែ។ ៦

**ប្រការ ៩~.** ប្រកាស និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០~.** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត និងប្រធានអង្គភាពពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**<u>ចម្លងជូន៖</u>**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- ក្រសួង / ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត(ជូនជ្រាប)
- ដូចប្រការ ៨ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ